ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

# បទប្បញ្ញត្តិ

# ស្តីពី

# ការសិក្សាសំរាប់និស្សិតថ្នាក់បរិញ្ញាបត្រ

**ការិយាល័យសិក្សា**

**ឆ្នាំ ២០០៩**

# បទប្បញ្ញត្តិ

# ស្តីពី

# ការសិក្សាសំរាប់និស្សិតថ្នាក់បរិញ្ញាបត្រ

# នៅ

# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

# ឆ្នាំ ២០០៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## បទប្បញ្ញត្តិ
## ស្តីពី
## ការសិក្សាសំរាប់និស្សិតថ្នាក់បរិញ្ញាបត្រ

**យោង :** -ព្រះរាជក្រម នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ

-ព្រះរាជក្រឹត្យ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-ប្រកាសលេខ ១៤៣៥អយក.ប្រកចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០០៧ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីលក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យលម្អិតសម្រាប់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សា ។

**ប្រការ១ : គោលបំណង**

**ក**-បទប្បញ្ញត្តិនេះ ធានាផ្តល់នូវយុត្តិធម៌ក្នុងការសិក្សា និងសំដៅធានាឱ្យបាននូវគុណភាពនៃការបណ្តុះបណ្តាល រួមទាំងសីលធម៌ផង សំរាប់និស្សិតទាំងអស់ ។

**ខ**-ការរៀបចំមុខវិជ្ជាបង្រៀន ត្រូវបានអនុមត័យល់ព្រម ដោយក្រុមប្រឹក្សាបណ្តុះបណ្តាលរបស់សាកលវិទ្យាល័យ ។ សមាសភាពរបស់ក្រុមប្រឹក្សាបណ្តុះបណ្តាលនេះ មាន ÷



| | |
|---|---|
| -សាកលវិទ្យាធិការ | ជាប្រធាន |
| -សាកលវិទ្យាធិការរង | ជាអនុប្រធាន |
| -ព្រឹទ្ធបុរស ឬ ព្រឹទ្ធបុរសរង | ជាសមាជិក |
| -នាយក ឬ នាយករងវិទ្យាស្ថាន | ជាសមាជិក |
| -ប្រធាន ឬ អនុប្រធានការិយាល័យសិក្សា | ជាសមាជិក |
| -ប្រធាន ឬ អនុប្រធានដេប៉ាតឺម៉ង់ | ជាសមាជិក ។ |

**ប្រការ២ : លក្ខខណ្ឌចុះឈ្មោះចូលរៀន**

**ក**-និស្សិត មានសិទ្ធិចុះឈ្មោះចូលរៀនឆ្នាំទី២បាន លុះត្រាតែមានវិញ្ញាបនបត្រឆ្នាំសិក្សាមូលដ្ឋាន ។

**ខ**-និស្សិត មានសិទ្ធិបន្តការសិក្សាឆ្នាំទី២ និងឆ្នាំបន្តបន្ទាប់រហូតបញ្ចប់កម្រិតបរិញ្ញាទៅតាមមុខជំនាញដែលបានជ្រើសរើសរួចមកហើយនៅឆ្នាំសិក្សាមូលដ្ឋាន ហើយមានឈ្មោះនៅក្នុងតលប់បញ្ជីដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និង កីឡា ។

**គ**-រាល់ដើមឆ្នាំសិក្សា និស្សិតឆ្នាំទី២ និងឆ្នាំបន្តបន្ទាប់ត្រូវមកចុះឈ្មោះចូលរៀន និងបង់វិភាគទានទ្រទ្រង់ការសិក្សា តាមការកំណត់របស់សាកលវិទ្យាល័យ ។

**ប្រការ៣ : បរិមាណនៃការសិក្សា**

**ក**-និស្សិត តម្រូវឱ្យរៀនគ្រប់មុខវិជ្ជា និងគ្រប់ក្រេឌីត(credit)ទាំងអស់តាមបរិមាណដែលបានកំណត់ក្នុងកម្មវិធីសិក្សា ។

**ខ**-និស្សិត ដែលប្រឡងធ្លាក់នូវមុខវិជ្ជាណាមួយនៅឆ្នាំមុន ត្រូវប្រឡងសងឡើងវិញ ទន្ទឹមជាមួយការប្រឡងយក នូវមុខវិជ្ជារៀនទាំងអស់ នៅឆ្នាំសិក្សាថ្មី ។

**គ**-រយៈពេលអប្បបរមានៃការសិក្សាមុខវិជ្ជាឯកទេស ទាំងក្នុងទីពិសោធន៍ និងនៅការដ្ឋាន មានចំនួន ១៨ម៉ោង ក្នុងមួយសប្តាហ៍ ដោយមិនគិតចំនួនម៉ោងភាសាបរទេស ។



**ប្រការ៤ : អវត្តមាន**

**ក**-ចាត់ទុកជាអវត្តមានមានច្បាប់ គឺការបានសុំច្បាប់ ឬសុំព្យួរការសិក្សា និងបានការយល់ព្រមទៅតាមមូលហេតុ ដូចជា :

-ឈឺធ្ងន់ ឬ សំរាលកូន ដោយមានលិខិតបញ្ជាក់ពីមន្ទីរពេទ្យ

-មានធុរៈចាំបាច់ក្នុងគ្រួសារ ។

**ខ**-ចាត់ទុកជាអវត្តមានគ្មានច្បាប់ គឺការឈប់ដោយមិនបានសុំច្បាប់អនុញ្ញាត ។

**ប្រការ៥ : ការតម្រូវឱ្យចូលថ្នាក់រៀន**

**ក**-និស្សិត ត្រូវបានតម្រូវឱ្យចូលថ្នាក់រៀនស្តាប់គ្រូគ្រប់ពេល នៃម៉ោងរៀនទាំងអស់ ។ ប៉ុន្តែ បើចំពោះមុខវិជ្ជាបង្រៀនណាមួយ និស្សិតអវត្តមានឥតច្បាប់ចាប់ពីមួយភាគបីនៃចំនួនម៉ោងឡើងទៅ( គ្រប់គ្រងដោយគ្រូទទួលបន្ទុកមុខវិជ្ជានោះ) ត្រូវចាត់ទុកថាមិនបានបំពេញលក្ខខណ្ឌឱ្យចូលប្រឡងមុខវិជ្ជានោះ ។ ចំពោះមុខវិជ្ជាដែលផ្សារភ្ជាប់នឹងការចុះស្រាវជ្រាវតាមមូលដ្ឋាន ការដ្ឋាន និងក្នុងសង្គម ឬ ការងារក្នុងទីពិសោធន៍ ឬកិច្ចការដែលដាក់ឱ្យនិស្សិតត្រូវបំពេញជាចាំបាច់ និស្សិតត្រូវតែមានវត្តមានដាច់ខាតគ្រប់ពេលដែលជាលក្ខខណ្ឌឱ្យចូលប្រឡង ។ ចំពោះមុខវិជ្ជាបង្រៀន ដែលជាម៉ោងណែនាំធ្វើកិច្ចការ ឬ លំហាត់ និស្សិតមិនអាចអវត្តមានឥតច្បាប់ លើសពី២០ភាគរយនៃចំនួនម៉ោងរៀនសរុបឡើយ ។ និស្សិតណាដែលមិនបានបំពេញលក្ខខណ្ឌឱ្យចូលប្រឡងត្រូវរៀនមុខវិជ្ជានោះឡើងវិញដោយស្វ័យប្រវត្តិ ។

**ខ**-ចាត់ទុកជាអវត្តមាន( មានច្បាប់) ចំពោះនិស្សិតណា ដែលបានដាក់ពាក្យសុំច្បាប់ជាលាយលក្ខណ៍អក្សរបានមុនថ្ងៃដែលខ្លួនឈប់ ដោយមានការបញ្ជាក់អំពីមូលហេតុ (ដូចចែងក្នុងប្រការ៤ ចំណុច"ក") និង កាលបរិច្ឆេទឈប់ច្បាស់លាស់ ហើយបានទទួលការយល់ព្រម ពីប្រធានដេប៉ាតឺម៉ង់ និងគណៈគ្រប់គ្រងសាកលវិទ្យាល័យ ។ លក្ខខណ្ឌឱ្យចូលប្រឡងរបស់និស្សិតប្រភេទនេះ គឺ ÷

-អវត្តមាន( មានច្បាប់) មិនលើសពី ៤០ ភាគរយនៃចំនួនម៉ោងបង្រៀនមុខវិជ្ជា

នីមួយៗ ទាំងទ្រឹស្តី និងកិច្ចការណែនាំ

-អនុញ្ញាតឱ្យធ្វើការងារពិសោធន៍ឡើងវិញ ដើម្បីបំពេញលក្ខខណ្ឌឱ្យចូលប្រឡង ។

## ប្រការ៦ : ការប្រឡង

### ក-សម័យប្រឡងទៀងទាត់

**១**-សម័យប្រឡងទាំងអស់ រៀបចំឡើងនៅដំណាច់ឆមាសនីមួយៗ សំរាប់គ្រប់មុខវិជ្ជាទាំងអស់ ក្នុងឆមាសនោះ លើកលែងតែនិស្សិតឆ្នាំទី៤ ដែលត្រូវប្រឡងបញ្ចប់ការសិក្សា ឬ ជ្រើសរើសការសរសេរសារណាបញ្ចប់ការសិក្សា ចំពោះនិស្សិតរៀនពូកែ ១០ ភាគរយនៃនិស្សិតសរុបក្នុងថ្នាក់ ។

-មុខវិជ្ជាប្រឡងបញ្ចប់ការសិក្សា( ចំពោះឆ្នាំទី៤) ត្រូវកំណត់យកមុខវិជ្ជាដែលសិក្សានៅឆមាសទី២ ។

**២**-និស្សិតទាំងអស់ ដែលបានគោរពបទប្បញ្ញត្តិ និង បទដ្ឋានផ្សេងៗ របស់សាកលវិទ្យាល័យ( បទបញ្ជាផ្ទៃក្នុង បទបញ្ជាក្នុងថ្នាក់រៀន ទីពិសោធន៍ បណ្ណាល័យ...) និង បានបំពេញលក្ខខណ្ឌអោយចូលប្រឡងដូចក្នុងប្រការ ៥ សុទ្ធតែអាចចូលប្រឡងក្នុងសម័យប្រឡងនោះ ។ ដោយឡែកនៅចុងឆមាសទី១ និស្សិតឆ្នាំទី៤ ត្រូវដាក់ពាក្យសុំចុះឈ្មោះប្រឡងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញា ។

**៣**-លទ្ធផលនៃការប្រឡង ត្រូវប្រកាសមួយខែក្រោយសម័យប្រឡង ។

### ខ-ការប្រឡងឡើងវិញ :

**១**-ក្នុងឆ្នាំសិក្សានីមួយៗ សម័យប្រឡងសំរាប់មុខវិជ្ជារៀននីមួយៗ មានពីរលើក ÷

-លើកទីមួយ ប្រព្រឹត្តទៅនៅដំណាច់ឆមាសទីមួយ ឬដំណាច់ឆមាសទីពីរនៃការបង្រៀនមុខវិជ្ជានោះ ។

-លើកទីពីរ ការប្រឡងឡើងវិញ ( ចំពោះនិស្សិតណាដែលប្រឡងធ្លាក់



លើកទី១) អាចប្រព្រឹត្តទៅ តែនៅក្នុងវិស្សមកាលនៃឆ្នាំសិក្សានោះ ហើយនៅឆ្នាំសិក្សាបន្ទាប់នាចុងឆមាសណាមួយនៃការបង្រៀនមុខវិជ្ជានោះ និងនៅក្នុងពេលវិស្សមកាលឆ្នាំសិក្សាបន្ទាប់ទៀតប៉ុណ្ណោះ ។ ជាសរុបចំពោះមុខវិជ្ជារៀននីមួយៗ និស្សិត មានសិទ្ធិចូលប្រឡងឡើងវិញ បានត្រឹមតែពលើកបន្តបន្ទាប់គ្នាប៉ុណ្ណោះ ។ បើការប្រឡងឡើងវិញលើកទី៣ នៅតែប្រឡងធ្លាក់លើមុខវិជ្ជាដដែល និស្សិតនោះត្រូវបញ្ឈប់ការសិក្សាជាស្ថាពរ ។

**២**-និស្សិតអនុញ្ញាតអោយឡើងថ្នាក់បាន ទាល់តែនៅដើមឆ្នាំសិក្សានីមួយៗ មានជំពាក់មុខវិជ្ជាដែលបានប្រឡងធ្លាក់មិនលើសពី ពីរមុខវិជ្ជាឡើយ ។ បើនិស្សិតណាបានប្រឡងធ្លាក់ ហើយនៅជំពាក់ចាប់ពីបីមុខវិជ្ជាឡើងទៅ ត្រូវឱ្យរៀនត្រួតថ្នាក់ឡើងវិញ ហើយត្រូវរៀន មុខវិជ្ជាទាំងអស់ ដែលមាននៅក្នុងឆ្នាំសិក្សានោះ ដូចនិស្សិតថ្មី ដែរ ។

**៣**-រាល់ការប្រឡងឡើងវិញរបស់និស្សិតឆ្នាំទី៤ សំរាប់មុខវិជ្ជានីមួយៗ និស្សិតត្រូវមកសុំចុះឈ្មោះប្រឡងឡើងវិញ និងបង់ប្រាក់សុំសិទ្ធិប្រឡងឡើងវិញតាមមុខវិជ្ជា និងតាមការកំណត់របស់សាកលវិទ្យាល័យ នៅការិយាល័យសិក្សាឱ្យបានយ៉ាងហោចណាស់ មួយសប្តាហ៍មុនពេលប្រឡង ។

### គ-ការសរសេរសារណាបញ្ចប់ការសិក្សា :

ការសរសេរសារណាបញ្ចប់ការសិក្សា ធ្វើឡើងទៅតាមលទ្ធភាពដេប៉ាតឺម៉ង់ និងមហាវិទ្យាល័យនីមួយៗ នៅដំណាច់ឆមាសទី១ ឆ្នាំទី៤: និស្សិតដែលត្រូវបានកត់សំគាល់ថារៀនពូកែ ត្រូវបានជ្រើសរើសឱ្យធ្វើសារណាបញ្ចប់ការសិក្សា ជំនួសការប្រឡងមុខវិជ្ជារៀនទាំងអស់នៅក្នុងឆមាសទី២នៃឆ្នាំទី៤ ។ ក្នុងករណីនេះនិស្សិតទាំងនោះ អាចចូលរៀនមុខវិជ្ជាទាំងឡាយ នៅក្នុងឆមាសទី២នេះបាន ដោយមិនបាច់ធ្វើការប្រឡងយកពិន្ទុនៅពេលបញ្ចប់ ប៉ុន្តែត្រូវសរសេរ និងឡើងការពារសារណាររបស់ខ្លួន នៅចំពោះមុខគណៈកម្មការវាយតំលៃសារណា ដែលចាត់តាំងឡើង ដោយក្រសួងអប់រំ យុវជន និងកីឡា ។ និស្សិតទាំងនេះ ក៏តម្រូវអោយរៀនបន្ថែម នូវវិធីសាស្រ្តស្រាវជ្រាវតាមការ



ចាត់ចែងរបស់ដេប៉ាតឺម៉ង់ ឬ មហាវិទ្យាល័យ ។

## ប្រការ៧ : ការមិនបានចូលប្រឡង

**ក**-ការមិនបានចូលប្រឡង ដោយមានច្បាប់អនុញ្ញាត តាមមូលហេតុសមស្របមិនបានត្រូវគិតថា បានប្រឡងធ្លាក់ទេ គឺមិនបានបន្ថយចំនួនសិទ្ធិសម័យប្រឡងរបស់បេក្ខជនឡើយ ។

**ខ**-បេក្ខជនដែលទទួលស្គាល់ថា អវត្តមានពេលប្រឡង ដោយមានច្បាប់អនុញ្ញាតចាំបាច់ ត្រូវធ្វើពាក្យសុំជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីមូលហេតុសមស្របនៃអវត្តមាន ទៅប្រធានដេប៉ាតឺម៉ង់ និងមានការយល់ព្រម ពីព្រឹទ្ធបុរសមហាវិទ្យាល័យ ឬគណៈគ្រប់គ្រងសាកលវិទ្យាល័យ ។

**គ**-ចំពោះអវត្តមានពេលប្រឡងដោយគ្មានច្បាប់អនុញ្ញាតត្រូវបានរាប់ថាបានប្រឡងធ្លាក់មួយលើកដែរ ។

## ប្រការ៨ : កំណត់រយៈពេលសិក្សា

**ក**-សំរាប់កម្មវិធីបណ្តុះបណ្តាលរយៈពេល៤ឆ្នាំ គឺថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន១ឆ្នាំ និង ឆ្នាំបន្តបន្ទាប់រយៈពេល៣ឆ្នាំទៀត និស្សិតអនុញ្ញាតអោយរៀនត្រួតថ្នាក់តែមួយឆ្នាំប៉ុណ្ណោះ ។

**ខ**-ចំពោះការបណ្តុះបណ្តាលទៀងទាត់ សំរាប់ប្រភេទបរិញ្ញាបត្រ និស្សិតមិនអនុញ្ញាត ឱ្យសិក្សា លើសពីរយៈពេល ៥ឆ្នាំឡើយ គឺរាប់ទាំងថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ។

**គ**-បើមានការអនុញ្ញាតអោយព្យួរការសិក្សាដោយមូលហេតុសមស្រប អាចពន្យាររយៈពេលនេះបន្ថែមមួយឆ្នាំទៀត រហូតដល់៦ឆ្នាំ សម្រាប់អោយបំពេញបរិញ្ញាបត្រ ។ និស្សិតអនុញ្ញាតអោយសុំព្យួរការសិក្សាត្រឹមតែមួយឆ្នាំប៉ុណ្ណោះ ។



## ប្រការ៩ : ការប្រគល់សញ្ញាបត្រ

**ក**-ក្រុមប្រឹក្សាបណ្តុះបណ្តាលរបស់សាកលវិទ្យាល័យ ត្រូវប្រជុំរៀបចំបញ្ជីឈ្មោះអ្នកជាប់សញ្ញាបត្រ មិនឱ្យលើសពី ពីរខែ ក្រោយសម័យប្រឡងបញ្ចប់ និងសម័យប្រឡងឡើងវិញ ក្នុងពេលវិស្សមកាល ។ បញ្ជីឈ្មោះនេះត្រូវបិទផ្សាយ ជាសាធារណៈ ។

**ខ**-ការប្រគល់សញ្ញាបត្រ ត្រូវរៀបចំមួយឆ្នាំមួយដង ។

**គ**-និស្សិត ត្រូវបង់ថ្លៃ សម្រាប់រៀបចំសញ្ញាបត្ររបស់ខ្លួន តាមការកំណត់របស់សាកលវិទ្យាល័យ ។

## ប្រការ១០ : តារាងសម្រង់ពិន្ទុ

សាកលវិទ្យាល័យ រក្សាតារាងសម្រង់ពិន្ទុចំពោះគ្រប់មុខវិជ្ជាដែលបានប្រឡងទាំងអស់ ទុកជាលទ្ធផលការសិក្សារបស់និស្សិតម្នាក់ៗ រួមមានទាំងពិន្ទុមុខវិជ្ជាដែលបានប្រឡងធ្លាក់ផង ។

## ប្រការ១១ : ព្រឹត្តិបត្រពិន្ទុ

**ក**-ព្រឹត្តិបត្រពិន្ទុ កត់ត្រានូវលទ្ធផលប្រឡងចុងក្រោយនៃមុខវិជ្ជារៀនទាំងអស់របស់និស្សិត ។

**ខ**-ព្រឹត្តិបត្រពិន្ទុ អាចចេញឱ្យបានតាមសណ្ឋានជាផ្លូវការ លុះត្រាតែមានការដាក់ពាក្យស្នើសុំទៅការិយាល័យសិក្សា និងបានបង់ប្រាក់សំរាប់ថ្លៃរៀបចំ ។ ព្រឹត្តិបត្រពិន្ទុនេះ ត្រូវបានខ្ចប់យ៉ាងជិត ក្នុងស្រោមសំបុត្រដែលបោះត្រា បិទមុខផ្ញើ ទៅអង្គភាពដែលពាក់ព័ន្ធ ។

**គ**-ពាក្យស្នើសុំព្រឹត្តិបត្រពិន្ទុ ត្រូវមានការចុះហត្ថលេខារបស់និស្សិត ឬ អតីតនិស្សិតសាមី ដោយមានភ្ជាប់មកជាមួយ នូវប័ណ្ណសំគាល់ខ្លួននិស្សិត រូបថតទំហំ ៤x៦ និងសញ្ញាបត្របរិញ្ញា ថតចំលង១ច្បាប់ ។

## ប្រការ១២ : ប្រព័ន្ធផ្ដល់ពិន្ទុ និង និទ្ទេស

| ពិន្ទុជាភាគរយ | និទ្ទេសជាអក្សរ | ពិន្ទុ និទ្ទេស | អត្ថន័យនិទ្ទេស |
|---|---|---|---|
| ៨៥ %–១០០ % | A | ៤.០០ | ប្រសើរណាស់ |
| ៨០ %–៨៤ % | $B^+$ | ៣.៥០ | ល្អប្រសើរ |
| ៧០ %–៧៩ % | B | ៣.០០ | ល្អ |
| ៦៥ %–៦៩ % | $C^+$ | ២.៥០ | ល្អបង្គួរ |
| ៥០ %–៦៤ % | C | ២.០០ | មធ្យម |
| ៤៥ %–៤៩ % | D | ១.៥០ | ខ្សោយ |
| ៤០ %–៤៤ % | E | ១.០០ | ខ្សោយណាស់ |
| <៤០ % | F | 0.00 | ធ្លាក់ |

## ប្រការ១៣ : អាកប្បកិរិយា

**១–** និស្សិតទាំងឡាយ ត្រូវមានអាកប្បកិរិយាថ្លៃថ្នូរ និងសំដែងអោយឃើញ នូវការគោរពចំពោះអ្នកដទៃ និងបរិស្ថានជុំវិញ ហើយចេះថែរក្សានូវវប្បធម៌ និងប្រពៃណីជាតិឱ្យបានល្អ មានចរិយា និងសីលធម៌ត្រឹមត្រូវ ។

**២–** និស្សិត តម្រូវអោយមានភាពស្មោះត្រង់ខាងបញ្ញា និង ចំណេះដឹង ក្នុងការរៀនសូត្រ ធ្វើកិច្ចការ និង ក្នុងពេលប្រឡង និស្សិតត្រូវប្រកាន់អាកប្បកិរិយាថ្លៃថ្នូរ មិនចំលងគ្នា មិនយកឯកសារចូលបន្ទប់ប្រឡង ។ល។ និស្សិតដែលបានប្រព្រឹត្តផ្ទុយពីបទបញ្ជាទាំងនេះត្រូវចាត់ទុកថា បានរំលោភលើបទបញ្ជារបស់សាកលវិទ្យាល័យ ហើយនិស្សិតនោះត្រូវបញ្ឈប់លែងឱ្យប្រឡង ឬ ដាក់ជូនគណៈមេប្រយោគសំរេច ។

**៣–** និស្សិត ត្រូវគោរពរាល់បទដ្ឋាន និងបទប្បញ្ញត្តិផ្សេងៗ ដែលរៀបចំឡើងដោយសាកលវិទ្យាល័យ មហាវិទ្យាល័យ ដេប៉ាតឺម៉ង់ និង ផ្នែកផ្សេងៗទៀត របស់សាកលវិទ្យាល័យ ។



**៤–** ការជក់បារី ការរំខាន និង ការបង្កឧបសគ្គដល់ការរៀនសូត្ររបស់អ្នកដទៃ ត្រូវបានហាមឃាត់ទៅតាមទីកន្លែងមួយចំនួន ដូចជា ក្នុងថ្នាក់រៀនទីពិសោធន៍ បណ្ណាល័យ និងការិយាល័យ ។

**៥–** ការលួចបន្លំ និងកេងប្រវ័ញ្ចទ្រព្យសម្បត្តិសាកលវិទ្យាល័យដោយនិស្សិត ត្រូវបានហាមឃាត់ជាដាច់ខាត ហើយត្រូវទទួលការវិនិច្ឆ័យ ពីក្រុមប្រឹក្សាវិន័យរបស់សាកលវិទ្យាល័យ ។

**៦–** ល្បែងស៊ីសងដាក់ប្រាក់ ឬមិនដាក់ប្រាក់ មិនអនុញ្ញាតឱ្យកើតមានក្នុងបរិវេណសាកលវិទ្យាល័យឡើយ ។

**៧–** និស្សិត ត្រូវផ្ដល់ព័ត៌មាន ដល់ការិយាល័យសិក្សា បើមានការប្ដូរស្ថានភាពផ្ទាល់ខ្លួន ដូចជារៀបអាពាហ៍ពិពាហ៍ ឬ ប្ដូរអាស័យដ្ឋានរបស់ខ្លួន ។

**៨–** និស្សិត ត្រូវបានហាមឃាត់ ក្នុងការយកអាវុធ គ្រឿងផ្ទុះ ឬគ្រឿងញៀនចូលក្នុងបរិវេណសាកលវិទ្យាល័យ និងហាមប្រើប្រាស់ទូរស័ព្ទដៃក្នុងម៉ោងរៀន ។

## ប្រការ១៤ : ក្រុមប្រឹក្សាវិន័យ

**១–** ក្រុមប្រឹក្សាវិន័យមួយ ត្រូវបានបង្កើតឡើង ហើយកោះប្រជុំ ទៅតាមស្ថានការណ៍ដែលមានករណីខុសឆ្គងរបស់និស្សិត ។

**២–** សាមាសភាពនៃក្រុមប្រឹក្សាវិន័យនេះ រួមមាន ÷

-គណៈគ្រប់គ្រងសាកលវិទ្យាល័យ

-ព្រឹទ្ធបុរសមហាវិទ្យាល័យដែលពាក់ពន្ធ័

-ប្រធានការិយាល័យសិក្សា



-ប្រធានដេប៉ាតឺម៉ង់ដែលពាក់ព័ន្ធ

-តំណាងសមាគមនិស្សិត ។

## ប្រការ១៥ : ការលុបឈ្មោះ

**១–** និស្សិត អាចត្រូវបញ្ឈប់ការសិក្សា ដោយលុបឈ្មោះចេញពីបញ្ជីនិស្សិតតាមមូលហេតុ ÷

-ការសិក្សា ( ប្រការ ៦ ខ១)

-ខុសវិន័យ ( ប្រការ ១៣)

**២–**និស្សិតដែលអវត្តមាន គ្មានច្បាប់មួយឆមាស និងពុំបានបំពេញលក្ខខណ្ឌឱ្យចូលប្រឡង ចំពោះមុខវិជ្ជាទាំងឡាយ នៅក្នុងឆមាសនោះ ត្រូវលុបឈ្មោះជាស្វ័យប្រវត្តិចេញពីបញ្ជីឈ្មោះនិស្សិត ។

រាជធានីភ្នំពេញ.ថ្ងៃទី០៣ ខែ មីនា ឆ្នាំ២០០៩

សាកលវិទ្យាធិការ

ឡោ_ឈីចអ៊ិច

ឃើញ និង ឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី... ខែឧសភាឆ្នាំ២០០៩

ភិត_ចំណាន